ក្រុមហ៊ុនទិនហេង និងសាំណេរ៉េតិអេរ៉ិត លោក មួត សៅរ៉ា និងក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សៀមរាប, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ២៦ អនក្រ.បក

## ស្តីពីការកែសំរួលមុខងារនិងភារកិច្ច

## និងការបង្កើតក្រុមអ្នកច្បាប់ និង នាយកដ្ឋាន

## សហប្រតិបត្តិការអន្តរជាតិ និង អាស៊ាន នៃ ក្រសួងទេសចរណ៍

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/១៥ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

www.pheakdeylaw.com

## សំរេច

### ជំពូកទី ១

### ការកែសំរួលមុខងារ និង ភារកិច្ច

**មាត្រា ១.-** កែសម្រួលចំណុចទី ១១ នៃមាត្រាទី ៣ នៃអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងទេសចរណ៍ ក្រសួងទេសចរណ៍ មានមុខងារនិងភារកិច្ចដូចតទៅ ៖

ចេញអាជ្ញាប័ណ្ណទេសចរណ៍ជូន ៖

- ក្រុមហ៊ុនទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ អាជីវកម្មដឹកជញ្ជូនទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរ សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋានទេសចរណ៍ និង កីឡាទេសចរណ៍ ។
- ភោជនីយដ្ឋាន រង្គសាល ហាងស្រា ឌីស្កូតែក ក្លឹបកំសាន្ត ម៉ាស្សា និង អាជីវកម្មសេវាកម្ម ផ្សេងៗទៀត ដែលមានឧបនិស្ស័យក្នុងការបំរើភ្ញៀវទេសចរ ។

### ជំពូកទី ២

### អំពីក្រុមអ្នកច្បាប់

**មាត្រា ២.-** បង្កើតក្រុមអ្នកច្បាប់ក្រសួងទេសចរណ៍ចំណុះក្រសួង ដែលមានតួនាទី និង ភារកិច្ចដូចខាងក្រោម ៖

- សិក្សាស្រាវជ្រាវ សហការជាមួយស្ថាប័នពាក់ព័ន្ធ តាក់តែងសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សារាចរ បទបញ្ញត្តិផ្សេងៗលើវិស័យទេសចរណ៍ ។
- សិក្សាស្រាវជ្រាវ ពិនិត្យសេចក្តីព្រាងកិច្ចសន្យានានា ដែលពាក់ព័ន្ធនឹងការងារទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-** ក្រុមអ្នកច្បាប់ដឹកនាំដោយប្រធានក្រុមមួយរូប និង មានអ្នកច្បាប់មួយចំនួនជាសមាជិកដែលជាមន្ត្រីមានក្របខ័ណ្ឌស្រាប់ ។

**មាត្រា ៤.-** ប្រធានក្រុមអ្នកច្បាប់មានឋានៈ និង បុព្វសិទ្ធិស្មើនឹង ប្រធាននាយកដ្ឋាន ។ ប្រធានក្រុមមានភារកិច្ចដឹកនាំ និង ចាត់ចែងអនុវត្តតួនាទី ភារកិច្ច ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ។

www.pheakdeylaw.com

## ជំពូកទី ៣

## នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង អាស៊ាន

មាត្រា ៥.- ដំឡើងការិយាល័យសហប្រតិបត្តិការអន្តរជាតិ ចំណុះនាយកដ្ឋានផែនការអភិវឌ្ឍន៍នៃអគ្គនាយកដ្ឋានទេសចរណ៍ ទៅជានាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង អាស៊ាននៃអគ្គនាយកដ្ឋានទេសចរណ៍ ដែលមានតួនាទី និង ភារកិច្ចដូចខាងក្រោម ៖

- សិក្សារៀបចំ ផែនការ និងសម្របសម្រួលអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងក្របខ័ណ្ឌការងារ អាស៊ាន
- អនុវត្តលើការងារ កិច្ចសហប្រតិបត្តិការ អន្តរជាតិ
- សហប្រតិបត្តិការជាមួយ អង្គការ សមាគម និង ស្ថាប័នអន្តរជាតិនានាលើវិស័យទេសចរណ៍ នៅក្នុងក្របខ័ណ្ឌអាស៊ាន និង អន្តរជាតិ
- ចងក្រង និង ធ្វើសេចក្តីព្រាង ព្រមទាំងរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង អនុស្សរណៈ កំណត់ហេតុ រវាងក្រសួងទេសចរណ៍នៃរាជរដ្ឋាភិបាលកម្ពុជា ជាមួយ ស្ថាប័នទេសចរណ៍ នៅក្នុងតំបន់ និង ប្រទេសនានាលើសកលលោក
- ទំនាក់ទំនងជាមួយស្ថានទូត និង ក្រសួងនានាលើការងារអន្តរជាតិ
- សហការរៀបចំការប្រជុំ សិក្ខាសាលា និង ពិធីផ្សេងៗជូនថ្នាក់ដឹកនាំក្រសួង

មាត្រា ៦.- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន ដឹកនាំដោយ ប្រធានមួយរូប និងអាចមាន អនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

មាត្រា ៧.- ការរៀបចំតួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ការិយាល័យនីមួយៗ ចំណុះក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង អាស៊ាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

## ជំពូកទី ៤

## អវសានបញ្ញត្តិ

មាត្រា ៨.- បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

www.pheakdeylaw.com

**មាត្រា ៩.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១៥៤ អនក្រ.បក

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

## សំរេច

**មាត្រា ១.-** ត្រូវបានប្រគល់ មេដាយសិរីវឌ្ឍនស្ថាបនាជាតិ ជូនលោកប្រធានអង្គការ SIPAR (SOUTIEN A L'INITIATIVE PRIVEE POUR L'AIDE A LA RECONSTRUCTION DES PAYS DU SUD-EST ASIATIQUE) ដែលបានជួយកសាងសង់អាគារបណ្ណាល័យមួយខ្នង នៅសាលាបឋមសិក្សាច្បារអំពៅទី១ ក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ ចំណាយអស់ទឹកប្រាក់ចំនួន ៩.៨០០ដុល្លារអាមេរិក ។